បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 19 ខែ 06 ឆ្នាំ 2013

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៦-៥-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧២ បំពាក់មេដាយ ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ជូនឯកឧត្តមឧត្តមសេនីយ៍ឯក **ហុក ឡុងឌី** | ១៣៤៥ |
| ១៦-៥-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៣ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ដាញេល អាឡាំង (SDANIEL ALAIN) | ១៣៤៦ |
| ១៨-៥-២០០១ | ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៥ បង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ | ១៣៤៧ |
| ២២-៥-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៨ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា | ១៣៥៤ |


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


| | | |
|---|---|---|
| ១៨-៥-២០០១ | -អនុក្រឹត្យលេខ ២១៥ អនក្រ.តត ស្តីពីការផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ | ១៣៦៨ |
| ២១-៥-២០០១ | -អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៦៩ |
| ២១-៥-២០០១ | -អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៣៧០ |
| ២១-៥-២០០១ | -អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ១៣៧១ |
| ២២-៥-២០០១ | -អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៣៧៨ |
| ២៣-៥-២០០១ | -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៧៩ |
| ២៣-៥-២០០១ | -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៨០ |
| ២៣-៥-២០០១ | -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៨១ |
| ២៣-៥-២០០១ | -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៨២ |
| ២៣-៥-២០០១ | -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៨៤ |
| ២៣-៥-២០០១ | -អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៨៥ |

២៣-៥-២០០១ -អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣៨៦

២៣-៥-២០០១ -អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣៨៨

២៣-៥-២០០១ -អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៣៨៩


## ២-សេចក្តីសំរេច


១៧-៥-២០០១ -សេចក្តីសំរេចលេខ ២៧ សសរ ស្តីពីការបង្កើតក្រុមចរចារវាងរាជរដ្ឋាភិបាល និង ធនាគារពិភពលោកសំរាប់គំរោងរំសាយទ័ព នៃកម្មវិធីជំនួយឧបត្ថម្ភអតីតយុទ្ធជន ១៣៩០

២២-៥-២០០១ -សេចក្តីសំរេចលេខ ២៨ សសរ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យការសាងសង់ស្ពាន ១៣៩២


## ៣-សារាចរណែនាំ


១៧-៥-២០០១ -សារាចរណែនាំលេខ ៨០ សរសន ស្តីពីការរៀបចំយុទ្ធនាការ "ផ្តល់ការគាំទ្រចំពោះកុមារ" ១៣៩៤


# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស


១៧-៥-២០០១ -ប្រកាសលេខ ៣២៩ ឧរថក.ឧ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ស៊ីណូ ណោឃ៉េរ ស្កាមេន (ខេមបូឌា) ខូ.អ៊ិលធីឌី តំណាងអោយលោក LAM KAM CHUEN SAMUEL សញ្ជាតិអង់គ្លេស បង្កើតរោងចក្រផលិតសំលៀកបំពាក់នាំចេញ ១៣៩៦


## ២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ប្រកាស


១៦-៥-២០០១ -ប្រកាសលេខ ១៩១ ប្រក.កសក ស្តីពីវិធានការទប់ស្កាត់ការនាំចូលសត្វគោ សត្វទំពារអៀង និងផលិតផលមានដើមកំណើតពីសត្វគោ សត្វទំពារអៀង ពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ១៣៩៨

# I_ ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

≈≈≈

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០១ ។

**ត្រាស់បង្គាប់**

**មាត្រា១** ._ ត្រូវបានបំពាក់មេដាយ **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម ឧត្តមសេនីយ៍ឯក **ហុក ឡុងឌី** អគ្គនាយក នៃអគ្គនាយកដ្ឋាន នគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**មាត្រា២** ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

≈≈≈

**ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៣**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៥/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា១ .-** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ដានៀល អាឡាំង** ( DANIEL ALAIN) សញ្ជាតិដើមបារាំង កើតនៅថ្ងៃទី ១១ ខែមករា ឆ្នាំ ១៩៤០ នៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង ។

**មាត្រា២** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

===

## ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

# គ្រាស់មខ្ពាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ " អនុលោមតាមមាត្រា ៨៧ និងមាត្រា ៨៨ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា២ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវបានបង្កើតឡើងជាក្រុមប្រឹក្សាកំណែទំរង់មួយ នៅក្នុងឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ សំរាប់ផ្នែកជាអាតភាពនៃវិមជ្ឈការ ។

## ជំពូកទី ២

## បេសកកម្ម និង សមាសភាព

**មាត្រា៣ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល អំពីបញ្ហានានាដូចមានចែងក្នុងមាត្រា ៨៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបញ្ហាជាក់ស្តែងដែលមានជាអាទិ៍ :

-ការអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-កិច្ចការនានាដែលមានការប៉ះពាល់មកលើឃុំ សង្កាត់ លើកលែងតែកិច្ចការបោះឆ្នោត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ការរៀបចំ និងអនុវត្តគោលនយោបាយវិមជ្ឈការ ។

**មាត្រា៤ .-**

ផ្អែកតាមសមត្ថកិច្ចដូចបានចែងក្នុងមាត្រា ៣ ខាងលើនេះ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ មានភារកិច្ចជាក់ស្តែងដែលមានជាអាទិ៍ :

-ទំនាក់ទំនង ពិភាក្សា និងសម្របសម្រួលជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងយន្តការកែទម្រង់រដ្ឋរបស់រាជរដ្ឋាភិបាល

-ធានាឱ្យមានការពិគ្រោះយោបល់ជាអន្តរក្រសួង និងការកសាងភាពជាដៃគូ ដើម្បីពិនិត្យមើលនូវបញ្ហា រួមសំដៅសំរេចអោយបាននូវកិច្ចព្រមព្រៀង ស្តីពីប្រតិបត្តិការ និងការទទួលខុសត្រូវរបស់ក្រសួងនីមួយៗ

-ពិនិត្យ និង រួមយោបល់លើខ្លឹមសារច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសំរេច សារាចរ ដីកាខេត្ត ក្រុង និងកិច្ចព្រមព្រៀងដែលកំពុងស្ថិតនៅជាធរមាន ដើម្បីស្នើយោបល់អំពីការធ្វើវិសោធនកម្ម ឬ កែសំរួលឱ្យស្រមស្របសំរាប់គាំទ្រ ការអនុវត្តន៍នយោបាយវិមជ្ឈការ ។

-ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ដែលមានការពាក់ព័ន្ធដល់ការងារឃុំ សង្កាត់ពិនិត្យផ្តល់យោបល់លើផែនការអភិវឌ្ឍន៍ កម្មវិធីអភិវឌ្ឍន៍ និងវិនិយោគ ព្រមទាំងសំណើអភិវឌ្ឍន៍ និងវិនិយោគពីប្រភពផ្សេងៗ ដែលមានការពាក់ព័ន្ធដល់ឃុំ សង្កាត់ និងទិដ្ឋភាពទាំងអស់នៃផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់

-សម្របសម្រួលដើម្បីឱ្យមានការអនុវត្តន៍ជាក់ស្តែងនូវបរិវេញ្ញវត្ថុ ទ្រព្យសម្បត្តិ និង សារពើពន្ធរបស់ឃុំ សង្កាត់

-សិក្សាស្រាវជ្រាវ និង កំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ និងការបង្កើតក្រុមប្រឹក្សា ឃុំ សង្កាត់រួមនៅពេលណាមួយសមស្រប

-សិក្សាអំពីកំណើនទីក្រុង និង នគរូបនីយកម្ម សំរាប់ជាមូលដ្ឋានបង្កើតគោលនយោបាយរចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រទីក្រុងឱ្យបានសមស្រប

-សម្របសម្រួលដើម្បីឱ្យមានការអនុវត្តន៍ជាក់ស្តែងនូវមុខងារ និង អំណាចរបស់ឃុំ សង្កាត់ រួម មានការផ្ទេរ (វិមជ្ឈការ) នៃមុខងារ "ផ្ទាល់ខ្លួន" និងប្រតិភូកម្ម (វិសហមជ្ឈការ) នៃមុខងារ "ជាភ្នាក់ ងារ" ពីរាជរដ្ឋាភិបាលទៅឃុំ សង្កាត់

-រៀបចំយុទ្ធសាស្ត្រនៃការផ្តល់ និងការចែកចាយសេវា រួមមានកិច្ចព្រមព្រៀងចែកចាយសេវា ការចាត់ចែងផ្តល់សេវា ក្នុងលក្ខណៈ សហប្រតិបត្តិការ ការធ្វើកិច្ចសន្យា និងលទ្ធកម្មរួមនៃអ្នកផ្តល់សេវា

-រៀបចំរចនាសម្ព័ន្ធរដ្ឋបាល និង យន្តការផ្តល់យោបល់នៃក្រុមប្រឹក្សាឃុំ សង្កាត់

-លើកកំពស់លទ្ធិប្រជាធិបតេយ្យ និងការគ្រប់គ្រងដោយមានការចូលរួមប្រកបដោយតម្លាភាព និងការទទួលខុសត្រូវ

-រៀបចំក្រមសីលធម៌របស់សមាជិកក្រុមប្រឹក្សា និង មន្ត្រីដែលបំពេញការងារក្នុងឃុំ សង្កាត់

-កំណត់នូវទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់

-កំណត់អំពីគោលការណ៍ និង លក្ខការណ៍នៃការតែងតាំងបុគ្គលិកដោយក្រុមប្រឹក្សាឃុំ សង្កាត់

-ធ្វើការពិនិត្យតាមដាន ផ្តល់ការគាំទ្រខាងបច្ចេកទេស និងត្រួតពិនិត្យលើនីត្យានុកូលភាព ការងាររបស់ឃុំ សង្កាត់

-ធ្វើអន្តរាគមន៍ក្នុងនាមរាជរដ្ឋាភិបាល ទៅលើការគ្រប់គ្រងមិនស្របច្បាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងពិនិត្យសំរេចលើការព្យួរការរំសាយ ព្រមទាំងលើកសំណើឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងនេះឡើងវិញ

-ចាត់វិធានការឱ្យមានការគ្រប់គ្រងបណ្តោះអាសន្នលើក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបំពេញភារកិច្ច ឬ អនុវត្តមុខងាររបស់ខ្លួន

-អប់រំ និង កសាងសមត្ថភាពធនធានមនុស្សរួមមាន ការបណ្តុះបណ្តាល ការរៀបចំកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និង មន្ត្រីដែលបានចាត់តាំង ។ រៀបចំកម្មវិធីតំរង់ទិស និង អប់រំដល់មន្ត្រីរាជការស៊ីវិលព្រមទាំងរៀបចំកម្មវិធីអប់រំ ដើម្បីមានការយល់ដឹងសំរាប់សាធារណជនទូទៅ

-ធ្វើការពិនិត្យតាមដាន និង វាយតម្លៃលើកិច្ចការនានា ដែលស្ថិតក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

**មាត្រា៥ .-**

គណៈកម្មាធិការនេះមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៤-រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៥-រដ្ឋមន្ត្រីក្រសួងរៀបចំដែន នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |

៦-រដ្ឋមន្ត្រីក្រសួងផែនការ ជាសមាជិក

៧-រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ជាសមាជិក

៨-អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ ជាសមាជិក

**មាត្រា៦ ._**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ចេញសេចក្តីសំរេច និង គោលការណ៍ណែនាំនានាផ្អែកតាមសមត្ថកិច្ចភារកិច្ចដែលបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ។

សេចក្តីសំរេច និង គោលការណ៍ណែនាំទាំងនោះ ត្រូវផ្អែកទៅលើឃុំ សង្កាត់ដែលមានធនធាន ឬមានសមត្ថកិច្ចហិរញ្ញវត្ថុ និងរដ្ឋបាលខុសគ្នា និងអាចរៀបចំជាដំណាក់កាល សំរាប់អនុវត្តបទប្បញ្ញត្តិណាមួយ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា៧ ._**

ផ្អែកតាមសមត្ថកិច្ចរបស់ខ្លួន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ច ស្នើយោបល់ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ស្របតាមនីតិវិធីជាធរមាន ។

**មាត្រា៨ ._**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវបង្កើតកម្មវិធី យុទ្ធសាស្ត្រ និង គំរោងការងារ ព្រមទាំងក្របខ័ណ្ឌពេលវេលាសំរាប់អនុវត្ត ។

**មាត្រា៩ ._**

រយៈពេល ៦០ ថ្ងៃ មុនបញ្ចប់អាណត្តិរបស់ខ្លួន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវលើកអនុសាសន៍ជូនរាជរដ្ឋាភិបាល អំពីការអនុវត្តនីបន្តទៀតនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តន៍គោលនយោបាយវិមជ្ឈការ ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ របៀបរបបការងារ និង លេខាធិការដ្ឋាន

**មាត្រា១០._**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួន ដើម្បីជាជំនួយការឱ្យខ្លួន ។

សមាសភាព និង មុខងារភារកិច្ចរបស់អនុគណៈកម្មការទាំងនោះ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា១១ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវរៀបចំ និង អនុម័តនូវបទប្បញ្ញត្តិ ដែលកំណត់ពីនីតិវិធីប្រជុំ និង របៀបរបបធ្វើការងាររបស់ខ្លួន ព្រមទាំងអនុគណៈកម្មការចំណុះនានា ។

បទប្បញ្ញត្តិដែលកំណត់អំពីនីតិវិធីខាងលើនេះ ត្រូវអនុម័តដោយសម្លេងពីរភាគបី នៃសមាជិកទាំងមូលរបស់គណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ ។

**មាត្រា១២ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើអញ្ជើញរដ្ឋមន្ត្រីនៃក្រសួង ឬ ប្រធាន នៃស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាល ឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬ ផ្តល់ពត៌មាន ឬ ផ្តល់កិច្ចសហការជួយដល់ការងាររបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា១៣ .-**

អង្គភាពចំណុះក្រសួងមហាផ្ទៃ ទទួលការងាររដ្ឋបាលមូលដ្ឋាន ដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ទីស្នាក់ការបំពេញការងាររបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ អនុគណៈកម្មការ និងលេខាធិការដ្ឋានតាំងនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ ។

**មាត្រា១៤ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## ប្រភពធនធានថវិកា

**មាត្រា១៥ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវមានគំរោងថវិកាប្រចាំដើម្បីបំពេញការងារ ដោយដាក់បញ្ចូលក្នុងគំរោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា១៦ .-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចទទួលជំនួយឧបត្ថម្ភផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងសំភារៈពីប្រភពក្នុងប្រទេស និងអន្តរជាតិសំរាប់គាំទ្រឃុំ សង្កាត់ និងសំរាប់អនុវត្តគោលនយោបាយវិមជ្ឈការ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចជួលអ្នកជំនាញការ អ្នកពិគ្រោះយោបល់ និង អ្នកបច្ចេកទេសជាតិ និង អន្តរជាតិ ។

ការសំរេចក្នុងការទទួលជំនួយខាងហិរញ្ញវត្ថុ សំភារៈ និង ការជួលអ្នកជំនាញការ អ្នកពិគ្រោះយោបល់ និង អ្នកបច្ចេកទេសជាតិ និង អន្តរជាតិ ត្រូវពិគ្រោះយោបល់ឯកភាពជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

នៅពេលចប់អាណត្តិរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ រាល់ចលនទ្រព្យ និង អចលនទ្រព្យត្រូវផ្ទេរទៅជូនក្រសួងមហាផ្ទៃ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៨ .-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង សមាសភាពដែលមានចែងក្នុងមាត្រា ៥ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១*

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

===

# ព្រះរាជក្រឹត្យ នស/រកត/០៥០១/១៧៨

## ស្តីពី

## លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ

## មន្ត្រីនគរបាលជាតិកម្ពុជា

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០០១

# ស្រាសមន្តាម

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មន្ត្រីនគរបាលជាតិទាំងអស់ត្រូវស្ថិតនៅក្នុងបទប្បញ្ញត្តិរបស់លក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា២ .-**

មន្ត្រីនគរបាលជាតិកម្ពុជាមានភារកិច្ចថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គម ដើម្បីបំរើផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋ ។

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវគោរពវិន័យយ៉ាងម៉ឺងម៉ាត់ មានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ និងអង់អាចក្លាហាន ហ៊ានធ្វើពលិកម្មនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះមាតុភូមិ ។

លក្ខន្តិកៈដោយឡែកនេះធានាសិទ្ធិ កាតព្វកិច្ច និងផលប្រយោជន៍ចំពោះមន្ត្រីនគរបាលជាតិកម្ពុជាគ្រប់រូប ។

**មាត្រា៣ .-**

ឋានានុក្រមរបស់នគរបាលជាតិកម្ពុជា រួមមាន ០៤ ប្រភេទ :

១-នាយនគរបាលថ្នាក់ឧត្តមសេនីយ៍

២-នាយនគរបាលជាន់ខ្ពស់

៣-នាយនគរបាល

៤-នាយនគរបាលរង

**មាត្រា៤ .-**

លំដាប់ថ្នាក់ឋានន្តរសក្តិនគរបាលជាតិកម្ពុជាមាន :

១-ឋានន្តរសក្តិនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ :

-នាយឧត្តមសេនីយ៍

-ឧត្តមសេនីយ៍ឯក

-ឧត្តមសេនីយ៍ទោ

-ឧត្តមសេនីយ៍ត្រី

២-ឋានន្តរសក្តិនាយនគរបាលជាន់ខ្ពស់ :

-វរសេនីយ៍ឯក

-វរសេនីយ៍ទោ

-វរសេនីយ៍ត្រី

៣-ឋានន្តរសក្តិនាយនគរបាល :

-អនុសេនីយ៍ឯក

-អនុសេនីយ៍ទោ

-អនុសេនីយ៍ត្រី

-នាយចំណង់

៤-ឋានន្តរសក្តិនាយនគរបាលរង :

-ព្រិន្ទបាលឯក

-ព្រិន្ទបាលទោ

-ពលបាលឯក

-ពលបាលទោ

-ពលបាលត្រី

**មាត្រា៥ .-**

ការតែងតាំង ការតម្លើងថ្នាក់ ការតម្លើងឋានន្តរសក្តិ ការផ្លាស់ប្តូរ ត្រូវសំរេចដោយ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសំរេច ។

ការបញ្ឈប់លែងអោយធ្វើការដោយបង្ខំ ការដាក់អោយចូលនិវត្តន៍មុនកំណត់ និងការដកហូតមុខតំណែងត្រូវសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសំរេច ។

## ជំពូកទី ២

## ការជ្រើសរើសអោយចូលធ្វើការ

**មាត្រា៦ .-**

ការជ្រើសរើសអោយចូលធ្វើការក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវធ្វើតាមរយៈ ការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត ឬ និងក្នុងចំណោមមន្ត្រីរាជការដែលមានក្របខ័ណ្ឌ ។ ចំនួន

នៃកន្លែងដែលត្រូវផ្តល់ក្នុងការប្រឡងប្រជែងសំរាប់សិស្ស និងនិស្សិត ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៧ .-**

ការប្រឡងជ្រើសរើសអោយចូលជានាយនគរបាល ត្រូវធ្វើចំពោះបេក្ខជនជាសិស្ស និស្សិតទាំងពីរប្រភេទដែលមានសញ្ញាប័ត្របរិញ្ញា ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើន ៣០ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ បើជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌ បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញា ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើនបំផុត ៣៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។

**មាត្រា៨ .-**

ការប្រឡងជ្រើសរើសអោយចូលជានាយនគរបាលរង ត្រូវធ្វើចំពោះបេក្ខជនជាសិស្ស និស្សិតទាំងពីរប្រភេទដែលមានសញ្ញាប័ត្រយ៉ាងទាបបំផុត មធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ និងមានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ បើជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌ បេក្ខជនត្រូវមានសញ្ញាប័ត្រយ៉ាងទាបបំផុតមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើនបំផុត ៣០ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។

**មាត្រា៩ .-**

បេក្ខជនទាំងពីរភេទដែលត្រូវបានប្រឡងជាប់ ជាសិស្សនាយនគរបាល និងជាសិស្ស នាយនគរ-បាលរងត្រូវបានទទួលការបណ្តុះបណ្តាលជាដំបូង ដោយក្រសួងមហាផ្ទៃ ។ រយៈពេលបណ្តុះបណ្តាលនេះ និងចាត់ទុកជារយៈពេលកម្មសិក្សារបស់សិស្សនាយនគរបាល និងសិស្សនាយនគរបាលរងទាំងនោះ ។

**មាត្រា១០ .-**

ក្រោយការបណ្តុះបណ្តាលសិស្សនាយនគរបាល និងសិស្សនាយនគរបាលរងត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ។ សិស្សនាយនគរបាលត្រូវបានតែងតាំងឋានន្តរសក្តិជានាយចំណង់ និងសិស្សនាយនគរបាលរង ត្រូវបានតែងតាំងឋានន្តរសក្តិជាពលបាលត្រី ។

## ជំពូកទី ៣

## បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ

**មាត្រា១១ .-**

មន្ត្រីនគរបាលជាតិកម្ពុជាមានសិទ្ធិទទួលប្រាក់បៀវត្សដែលចំនួនទឹកប្រាក់ កំណត់ទៅតាមឋានន្តរសក្តិ ។

មន្ត្រីនគរបាលជាតិកម្ពុជា អាចទទួលប្រាក់បន្ថែមបំណាច់ពិសេស ផ្តល់ជូនទៅតាមប្រភេទមុខងារតំណែងដែលខ្លួនបានបំពេញ ។

ប្រាក់បៀវត្ស ប្រាក់បំណាច់ពិសេស និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត នឹងត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

**មាត្រា១២ .-**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវបានទទួលរបបនៃការឈប់ប្រចាំឆ្នាំ ការឈប់សំរាកព្យាបាលជម្ងឺ និងឈប់សំរាកផ្សេងៗទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## ការតម្លើងឋានន្តរសក្តិ

**មាត្រា១៣ .-**

ការតម្លើងឋានន្តរសក្តិរបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវគិតទៅលើលក្ខណៈសម្បត្តិ និងអតីតភាពការងារកន្លងមក ។

**មាត្រា១៤ .-**

លក្ខណៈសម្បត្តិសំរាប់ពិនិត្យក្នុងការស្នើតម្លើងឋានន្តរសក្តិ ត្រូវផ្អែកតាមព្រឹត្តិប័ត្រពិន្ទុមន្ត្រីនគរបាលជាតិកម្ពុជា ដូចមានកំណត់ខាងក្រោម :

១-ការគោរពវិន័យ

២-ការចាត់តាំង

៣-កិរិយាមាយាទ និងសីលធម៌

៤-សមត្ថភាពបំពេញភារកិច្ច

៥ ...ក់ទំនងការងារ

...ុខភាព

៧-ភាសាបរទេស (ភាសាបារាំង ឬអង់គ្លេស)

មណ្ឌលឯកសារជាតិ
ថ្ងៃទី____ ខែ____ ឆ្នាំ____

**មាត្រា១៥ ._**

ការតម្លើងឋានន្តរសក្តិរបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវអនុវត្តទៅតាមវេនជ្រើសរើស ។ ប៉ុន្តែមិនអាចអនុវត្តបានប្រសិនបើមន្ត្រីនគរបាលជាតិកម្ពុជាណាបំរើការងារមិនគ្រប់តាមល័ក្ខខ័ណ្ឌ និង រយៈពេលកំណត់ ។ រយៈពេលដែលត្រូវតម្លើងឋានន្តរសក្តិដូចខាងក្រោម :

**ក_នាយនគរបាលរង :**

| ឋានន្តរសក្តិ | រយៈពេលបំរើការងារក្នុងឋានន្តរសក្តិមួយថ្នាក់ដើម្បីអាចតម្លើងបាន |
|---|---|
| ពលបាលត្រី | ២ ឆ្នាំ |
| ពលបាលទោ | ២ ឆ្នាំ |
| ពលបាលឯក | ២ ឆ្នាំ |
| ព្រិន្ទបាលទោ | ២ ឆ្នាំ |
| ព្រិន្ទបាលឯក | ២ ឆ្នាំ |

*ចំពោះនាយនគរបាលរងថ្នាក់ព្រិន្ទបាលឯក ដែលមានអតីតភាព ២ ឆ្នាំឡើង មានសិទិប្រឡង ជ្រើសរើស និងទទួលការបណ្តុះបណ្តាលបន្ថែមជានាយនគរបាលតាមការកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ និងតាមតម្រូវការចាំបាច់របស់នគរបាលជាតិកម្ពុជា ។

**ខ_នាយនគរបាល :**

| ឋានន្តរសក្តិ | រយៈពេលបំរើការងារក្នុងឋានន្តរសក្តិមួយថ្នាក់ដើម្បីអាចតម្លើងបាន |
|---|---|
| នាយចំណង់ | ១ ឆ្នាំ |
| អនុសេនីយ៍ត្រី | ២ ឆ្នាំ |
| អនុសេនីយ៍ទោ | ៣ ឆ្នាំ |
| អនុសេនីយ៍ឯក | ៣ ឆ្នាំ |

*ចំពោះនាយនគរបាលថ្នាក់អនុសេនីយ៍ឯក ដែលមានអតីតភាព ៣ ឆ្នាំឡើង មានសិទ្ធិប្រឡង ជ្រើសរើស និងទទួលការបណ្តុះបណ្តាលបន្ថែមជានាយនគរបាលជាន់ខ្ពស់បាន តាមការកំណត់ដោយ ប្រកាសរបស់ក្រសួងមហាផ្ទៃ និងតាមតម្រូវការចាំបាច់របស់នគរបាលជាតិកម្ពុជា ។

**គ-នាយនគរបាលជាន់ខ្ពស់ :**

| ឋានន្តរសក្តិ | រយៈពេលបំរើការងារក្នុងឋានន្តរសក្តិមួយថ្នាក់ដើម្បីអាចតម្លើងបាន |
|---|---|
| វរសេនីយ៍ត្រី | ៥ ឆ្នាំ |
| វរសេនីយ៍ទោ | ៥ ឆ្នាំ |
| វរសេនីយ៍ឯក | ៦ ឆ្នាំ |

*ចំពោះនាយនគរបាលជាន់ខ្ពស់ថ្នាក់វរសេនីយ៍ឯក ដែលមានអតីតភាព ៦ ឆ្នាំឡើង ទើបអាចធ្វើសំណើតែងតាំងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ ដោយយោងទៅតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ ។

ចំពោះមន្ត្រីនគរបាលជាតិកម្ពុជាដែលពលី ត្រូវបានតម្លើង ឋានន្តរសក្តិមួយថ្នាក់ជាកិច្ចបច្ចាមរណៈ ។

**មាត្រា១៦ .-**

ការតម្លើងឋានន្តរសក្តិ ត្រូវប្រព្រឹត្តទៅតាមសំដាប់ថ្នាក់មួយសក្តិម្តងៗ ហើយពុំអាចមានការតែងតាំងជាឋានន្តរសក្តិកិត្តិយសបានឡើយ ។ ក្នុងករណីមន្ត្រីនគរបាលជាតិកម្ពុជាណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេសត្រូវបានតម្លើងឋានន្តរសក្តិមួយថ្នាក់ដោយពុំគិតពីលក្ខ័ខណ្ឌ និងអតីតភាពឡើយ ។

**មាត្រា១៧ .-**

ការតម្លើងឋានន្តរសក្តិរបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវប្រព្រឹត្តទៅតាមលំដាប់នៃបញ្ជី អតីតភាព ។

ពុំអាចត្រូវតម្លើងឋានន្តរសក្តិបាន ក្នុងករណីពុំមានឈ្មោះនៅក្នុងតារាងតម្លើងឋានន្តរសក្តិ ដែលត្រូវរៀបចំឡើងក្នុងមួយឆ្នាំម្តងនោះទេ ។

ក្នុងករណីដែលមិនបានជាប់ឈ្មោះនៅក្នុងបញ្ជីតម្លើងឋានន្តរសក្តិប្រចាំឆ្នាំទេ មន្ត្រីនគរបាលជាតិកម្ពុជានោះ ត្រូវបានទទួលសិទ្ធិចុះឈ្មោះមុនគេបង្អស់ តាមលេខរៀងនៅក្នុងតារាងតម្លើងឋានន្តរសក្តិនាឆ្នាំបន្ទាប់ លើកលែងតែរដ្ឋមន្ត្រីក្រសួងមហាផ្ទៃសំរេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុសមផល ពីមន្ត្រីដែលមានសមត្ថកិច្ច ។

**មាត្រា១៨ .-**

ការតែងតាំងឋានន្តរសក្តិ ត្រូវសំរេចដោយ :

-ព្រះរាជក្រឹត្យ សំរាប់ថ្នាក់ឧត្តមសេនីយ៍

-អនុក្រឹត្យ សំរាប់ថ្នាក់វរសេនីយ៍ឯក

-ប្រកាសរបស់ក្រសួងមហាផ្ទៃ សំរាប់ថ្នាក់វរសេនីយ៍ចុះ

## ជំពូកទី ៥

## សិទ្ធិ ភារកិច្ច និងការកិច្ចទទួលខុសត្រូវ

**មាត្រា១៩ .-**

មន្ត្រីនគរបាលជាតិកម្ពុជាមានសិទ្ធិ និងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត ។ ក៏ប៉ុន្តែការប្រើសិទ្ធិនិងសេរីភាពខ្លះ ត្រូវមានកំរិតស្របតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ ។

**មាត្រា២០ .-**

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវមានអព្យាក្រឹត្យភាពក្នុងមុខនាទី ក្នុងសកម្មភាពការងារ និងហាមឃាត់ការប្រើមុខងារ ការបំពេញភារកិច្ច និងប្រើប្រាស់មធ្យោបាយ សំភារៈរបស់រដ្ឋ ដើម្បីបំរើសកម្មភាព និងផលប្រយោជន៍គណបក្សនយោបាយណាមួយ ។

**មាត្រា២១ .-**

មន្ត្រីនគរបាលជាតិកម្ពុជាម្នាក់ៗ អាចមានគំនិត ឬជំនឿដែលមានលក្ខណៈជាទស្សនៈវិជ្ជា ឬនយោបាយផ្ទាល់ខ្លួនបាន ប៉ុន្តែពុំអាចសំដែងជាសាធារណៈបានឡើយ ។ វិធាននេះ មិនហាមឃាត់ដល់ការប្រតិបត្តិដោយសេរីនូវជំនឿសាសនា ក្នុងបរិវេណអង្គភាពរបស់កងកំលាំងនគរបាលជាតិកម្ពុជាឡើយ ។

**មាត្រា២២ .-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលចង់បកស្រាយជាសាធារណៈ ជាអាទិ៍ ការសរសេរ ការធ្វើសន្និសីទ ឬសេចក្តីថ្លែងការណ៍នូវបញ្ហានយោបាយឬការសម្ងាត់របស់នគរបាលជាតិ ត្រូវបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា២៣ .-**

មន្ត្រីនគរបាលជាតិកម្ពុជាមានកាតព្វកិច្ចរក្សាការសម្ងាត់ជាតិ និងរក្សាការសម្ងាត់អំពីហេតុការណ៍ ពត៌មានដែលខ្លួនបានដឹងក្នុងពេលបំពេញភារកិច្ច ឬការសម្ងាត់ខាងវិជ្ជាជីវៈ ។ ការពង្វាង ឬការផ្តល់ពត៌មាន លិខិតស្នាម ឬឯកសារនៃសេវាផ្ទុយពីបទបញ្ជាទៅអោយតតិយជន ត្រូវហាមឃាត់ ។

**មាត្រា២៤ .-**

ការផ្សព្វផ្សាយក្នុងបរិវេណអង្គភាពរបស់នគរបាលជាតិកម្ពុជា ទោះជារូបភាពណាក៏ដោយដែលនាំអោយខូចដល់ទឹកចិត្ត ឬវិន័យ ត្រូវបានហាមឃាត់ទៅតាមល័ក្ខខ័ណ្ឌ ដែលមានចែងដោយ បទវិន័យរបស់នគរបាលជាតិកម្ពុជា ។

**មាត្រា២៥ .-**

មន្ត្រីនគរបាលជាតិកម្ពុជាអាចប្រមូលផ្តុំគ្នាបង្កើតជាក្រុមវិជ្ជាជីវៈ ដែលមានលក្ខណៈជាសមាគម ឬចូលរួមជាសមាជិកក្រុមវិជ្ជាជីវៈណាមួយ ដែលសមស្របទៅតាមបទវិន័យរបស់នគរបាលជាតិកម្ពុជា។

**មាត្រា២៦ .-**

មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវទទួលបញ្ជាទៅបំរើការងារនៅគ្រប់កាលៈទេសៈ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។ ប្រសិនបើការចាត់តាំងនោះបណ្តាលអោយជួបការលំបាក ដែលចាំបាច់ត្រូវការឧបត្ថម្ភ គ្រប់ថ្នាក់ដែលមានសមត្ថកិច្ច ត្រូវធានាផ្តល់អោយទៅតាមប្រភេទនៃការលំបាកនោះ ។

**មាត្រា២៧ .-**

មន្ត្រីនគរបាលជាតិកម្ពុជា អាចនឹងត្រូវបានផ្លាស់ប្តូរភារកិច្ច ទៅតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ ។

**មាត្រា២៨ .-**

មន្ត្រីនគរបាលជាតិកម្ពុជា មានសិទ្ធិសុំច្បាប់ឈប់សំរាកដោយមានបៀវត្ស រយៈពេលនិងបែបបទអនុញ្ញាតច្បាប់ត្រូវកំណត់ដោយបទវិន័យរបស់នគរបាលជាតិកម្ពុជា ។ ពេលចាំបាច់អាចកោះហៅជាបន្ទាន់នូវមន្ត្រីនគរបាលជាតិកម្ពុជា ដែលកំពុងឈប់សំរាកច្បាប់អោយចូលខ្លួនមកវិញ ។

**មាត្រា២៩ .-**

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវគោរព និងអនុវត្តរាល់បញ្ជាដោយស្មារតីទទួលខុសត្រូវ ។ បញ្ជាណាដែលមានភាពច្បាស់ក្រឡែត ផ្ទុយពីច្បាប់ ឬផ្ទុយពីអនុសញ្ញាអន្តរជាតិ ត្រូវហាមឃាត់ ។ ក្នុងករណីនេះ អ្នកបញ្ជាក្តី ឬអ្នកអនុវត្តក្តី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

**មាត្រា៣០ .-**

មន្ត្រីនគរបាលជាតិកម្ពុជាទាំងអស់ត្រូវទទួលខុសត្រូវអំពីកំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន ។

ក្នុងករណីដែលមានពាក្យបណ្តឹងពីតតីយជនចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ពីកំហុសក្នុង ការបំរើសេវាដែលមិនមែនជាកំហុសផ្ទាល់របស់មន្ត្រីនគរបាលជាតិកម្ពុជា រដ្ឋត្រូវការពារមន្ត្រីនគរបាលជាតិកម្ពុជារូបនោះចំពោះសំណងផ្នែករដ្ឋប្បវេណី ។

មន្ត្រីនគរបាលជាតិកម្ពុជាបំពេញភារកិច្ចដែលមានការគំរាមកំហែង ឬវាយប្រហារដោយប្រការណាមួយពីសំណាក់ជនណាម្នាក់ដែលមិនមែនជាកំហុសផ្ទាល់ខ្លួនត្រូវបានរដ្ឋការពារទទួលសងនូវការខូចខាត និងចេញមុខប្តឹងទៅតុលាការ ។

**មាត្រា៣១ .-**

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវហាមឃាត់ជាដាច់ខាត :

១-យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២-យកឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុតគំរាមកំហែងបំពានសិទ្ធិពលរដ្ឋ ។

៣-ប្រកបមុខរបរណេដែលនាំអោយប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់នគរបាលជាតិកម្ពុជា ។

៤-ចូលជាសមាជិកនៃក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល ។

ចំពោះមុខរបរណាដែលត្រូវបានអនុញ្ញាត និង មុខរបរណាដែលនាំអោយប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីនគរបាលជាតិកម្ពុជា ហើយដែលត្រូវបានហាមឃាត់នោះ នឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៣២ .-**

មន្ត្រីនគរបាលជាតិកម្ពុជាត្រូវបានទទួលពិន្ទុមួយឆ្នាំម្តងសំរាប់ពិនិត្យតម្លើងថ្នាក់ ឬឋានន្តរសក្តិ។ ប្រធានអង្គភាពផ្ទាល់ជាអ្នកដាក់ពិន្ទុ និងមូលវិចារណ៍ ។

**មាត្រា៣៣ .-**

មន្ត្រីនគរបាលជាតិកម្ពុជាណាដែលមានស្នាដៃ ត្រូវបានទទួលការលើកសរសើរជូនរង្វាន់តាមការកំណត់របស់ក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល ។

## ជំពូកទី ៦

## ការចូលនិវត្តន៍

**មាត្រា៣៤ .-**

មន្ត្រីនគរបាលជាតិកម្ពុជាទាំងពីរភេទ ដែលបានបំរើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ហើយត្រូវបានដាក់អោយចូលនិវត្តន៍ :

ក-នៅពេលដល់អាយុ ៥៥ ឆ្នាំ ចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ដែលមានឋានន្តរសក្តិថ្នាក់វរសេនីយ៍ចុះ ។

ខ-នៅពេលដល់អាយុ ៦០ ឆ្នាំ ចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ដែលមានឋានន្តរសក្តិថ្នាក់វរសេនីយ៍ឯកឡើង ។

ការដាក់អោយចូលនិវត្តន៍ត្រូវសំរេចដោយ :

-ព្រះរាជក្រឹត្យ ចំពោះថ្នាក់ឧត្តមសេនីយ៍

-អនុក្រឹត្យ ចំពោះថ្នាក់វរសេនីយ៍ឯក

-ប្រកាសរបស់ក្រសួងមហាផ្ទៃ ចំពោះថ្នាក់វរសេនីយ៍ទោចុះ

**មាត្រា៣៥ .-**

របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងាររបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧

## ទណ្ឌកម្ម

**មាត្រា៣៦ .-**

មន្ត្រីនគរបាលជាតិកម្ពុជា ក្នុងករណីមានកំហុស ត្រូវទទួលទណ្ឌកម្មរបស់នគរបាលជាតិកម្ពុជាដូចខាងក្រោម ដោយមិនគិតពីការផ្តន្ទាទោសតាមផ្លូវតុលាការ ។

១-ទណ្ឌកម្មដែលកំណត់ដោយបទវិន័យរបស់នគរបាលជាតិកម្ពុជា ។

២-ទណ្ឌកម្មដែលកំណត់ក្នុងព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជាដែលមានចែងក្នុងមាត្រា ៣៩-៤០-៤១ និង ៤២ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៣៧ .-**

មុននឹងដាក់ទណ្ឌកម្មតាមព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជាត្រូវសុំយោបល់ពីក្រុមប្រឹក្សាវិន័យជាមុន ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាវិន័យ និងនីតិវិធីនៃការអនុវត្តន៏វិន័យចំពោះមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៣៨ .-**

ក្រោយទទួលបានយោបល់ពីក្រុមប្រឹក្សាវិន័យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចសំរេចដាក់ទណ្ឌកម្មដែលមានចែងក្នុងមាត្រា ៣៩ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៣៩ .-**

ទណ្ឌកម្មដែលត្រូវអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជាមាន :

ការលុបឈ្មោះចេញពីតារាងតម្លើងឋានន្តរសក្តិ

-ការដកមុខដំណែងដោយអោយនៅក្នុងស្ថានភាពអសកម្ម

-ការដាក់អោយនៅទំនេរគ្មានបៀវត្ស មិនអោយលើសពីមួយឆ្នាំ

-ការបន្ថយឋានន្តរសក្តិ ឬថ្នាក់ មួយថ្នាក់ ឬច្រើនថ្នាក់

-ការដាក់អោយចូលនិវត្តន៏មុនកំណត់

-ការលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

**មាត្រា៤០ .-**

ការដកមុខដំណែងដោយដាក់ក្នុងស្ថានភាពអសកម្ម ត្រូវអនុវត្តចំពោះតែមន្ត្រីនគរបាលជាតិកម្ពុជាណាដែលមិនមានសិទ្ធិចូលនិវត្តន៏ភ្លាមៗ ។ ការដកមុខដំណែងមិនអាចមានរយៈពេលលើសពីមួយឆ្នាំឡើយ ។

នៅពេលផុតកំណត់នៃរយៈពេលដែលស្ថិតនៅក្នុងស្ថានភាពអសកម្ម មន្ត្រីនគរបាលជាតិកម្ពុជានោះ ត្រូវដាក់អោយនៅក្នុងស្ថានភាពសកម្មវិញ ។

រយៈពេលអសកម្មដោយការដកមុខដំណែង មិនត្រូវយកមកគិតក្នុងការតម្លើងឋានន្តរសក្តិទេ។

**មាត្រា៤១ .-**

មន្ត្រីនគរបាលជាតិកម្ពុជាដែលត្រូវបន្ថយឋានន្តរសក្តិ ឬថ្នាក់ត្រូវបញ្ចូលទៅក្នុងឋានន្តរសក្តិថ្មី ឬថ្នាក់ថ្មីចាប់គិតពីថ្ងៃដែលមានការសំរេចជាផ្លូវការ ។

**មាត្រា៤២ .-**

ការលុបឈ្មោះមន្ត្រីនគរបាលជាតិកម្ពុជាចេញពីក្របខ័ណ្ឌ អនុវត្តបានដោយមិនគិតពីអតីតភាពការងារ ។

**មាត្រា៤៣ .-**

អនុក្រឹត្យ ឬប្រកាសដែលសំរេចចោទប្រកាន់ អំពីកំហុសខាងវិន័យនាំអោយមានការផ្អាកការងារមន្ត្រីនគរបាលជាតិកម្ពុជាជាបណ្តោះអាសន្ន តែមិនមានការបន្ថយបៀវត្សទេ ។

**មាត្រា៤៤ .-**

ការសំរេចផ្អាកការងារនៃមន្ត្រីនគរបាលជាតិកម្ពុជាជាបណ្តោះអាសន្ន មានកំណត់ត្រឹមចំនួន ៣ ខែ ប៉ុន្តែបើជាករណីពិសេស អាចសំរេចអោយបន្តជាថ្មីទៀតបានកំណត់ ១ ខែម្តង ប៉ុន្តែការបន្តនោះមិនត្រូវលើសពី ៣ ដងឡើយ ។

## ជំពូកទី ៨

## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា៤៥ .-**

ក្នុងករណីដែលមន្ត្រីនគរបាលជាតិកម្ពុជាណាម្នាក់ ប្រព្រឹត្តបទល្មើសព្រហ្មទ័ណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹង អំពីការចោទប្រកាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ ។

បើមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្ន លើមន្ត្រីនគរបាលជាតិកម្ពុជាណាមួយនោះ ព្រះរាជអាជ្ញា ឬចៅក្រមមានសមត្ថកិច្ច ត្រូវរាយការណ៍ជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៤៦ .-**

មន្ត្រីនគរបាលជាតិកម្ពុជាណាដែលកំពុងជាប់ការចោទប្រកាន់ទៅតុលាការជំនុំជំរះអាចត្រូវផ្អាកពីមុខងារសិនក្នុងករណីចាំបាច់ ។

ក្នុងករណីដែលមន្ត្រីនគរបាលជាតិកម្ពុជា ត្រូវផ្អាកពីការងារដោយផ្អាកបៀវត្ស មន្ត្រីនគរបាលជាតិកម្ពុជានោះ ត្រូវបានទទួលអោយចូលធ្វើការវិញភ្លាម ដោយគិតពីអតីតភាព ឋានន្តរសក្តិ សោធននិវត្តន៍ និងទទួលបៀវត្សប្រតិសកម្មផង បើតុលាការប្រកាសអោយរួចខ្លួនជាស្ថាពរ ។

**មាត្រា៤៧ ._**

ការផ្តន្ទាទោសជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយឥតព្យួរទោស បណ្តាលអោយមានការលុបឈ្មោះចេញពីក្របខ័ណ្ឌនគរបាលជាតិដល់មន្ត្រីនគរបាលជាតិកម្ពុជានោះ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

មន្ត្រីនគរបាលជាតិកម្ពុជា ដែលឥតវ៉ាសុំឧទ្ធរណ៍ត្រូវដាក់អោយនៅទំនេរគ្មានបៀវត្សជាបណ្តោះអាសន្នដោយស្វ័យប្រវត្តិ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា៤៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤៩ ._**

នាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៥០ ._**

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

## អនុក្រឹត្យលេខ ២១៥ អនក្រ.តត
## ស្តីពីការផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១** .- ផ្លាស់ប្តូរភារកិច្ចលោក **អ៊ុំ សារិទ្ធ** អភិបាលរងទី ១ ខេត្តស្ទឹងត្រែង អោយមកទទួលភារកិច្ចនៅស្ថាប័នដើមវិញ ។

**មាត្រា២** .- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយ

បណ្ណសារជាតិ
ថ្ងៃទី______ ខែ______ ឆ្នាំ________

មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

## អនុក្រឹត្យលេខ ២១៦ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីកាតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជនចំនួន ០៩ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងជួសជុលសមិទ្ធផលនានា មានសាលារៀន ព្រះវិហារ កុដិ ក្លោងទ្វារ និងស្រះទឹក នៅក្នុងវត្តចិញ្ចៀង វត្តសែនភាស វត្តក្បាលសំរោង និងវត្តក្តីទន្ទឹម ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

១-ព្រះតេជគុណ **ឡុង នៅ** ព្រះបាល័ដគណខេត្ត និងជាព្រះអនុគណស្រុក

ប្រាក់ចំនួន២១.០០០ ដុល្លារអាមេរិក

២-ព្រះតេជគុណ **ឌី ម៉ុក** ព្រះចៅអធិការវត្តចិព្លែង ប្រាក់ចំនួន ២៥.១០០ ដុល្លារអាមេរិក

៣-លោក **ខៀវ សារុណ** ប្រធានការិយាល័យរដ្ឋបាល មន្ទីរសាធារណការរាជធានីភ្នំពេញ ប្រាក់ចំនួន ១៣.១០០ ដុល្លារអាមេរិក

៤-លោក **ពោធ ឈួន** អភិបាលស្រុករងសំរោង ប្រាក់ចំនួន ១២.២០០ ដុល្លារអាមេរិក

៥-លោក **មាស ផន** គណៈកម្មការវត្តចិព្លែង ប្រាក់ចំនួន ១១.៥០០ ដុល្លារអាមេរិក

៦-លោក **យក់ មន** គណៈកម្មការវត្តសែនភាស ប្រាក់ចំនួន ១១.០៥០ ដុល្លារអាមេរិក

៧-លោក **ហោ ឡេង** គណៈកម្មការវត្តចិព្លែង ប្រាក់ចំនួន ១០.៥០០ ដុល្លារអាមេរិក

៨-លោក **ឯក សំអាង** ប្រធានការិយាល័យកសិកម្ម ស្រុកសំរោង ប្រាក់ចំនួន ១០.៣០០ ដុល្លារអាមេរិក

៥-លោក **កែវ សាង** គណៈកម្មការវត្តក្បាលសំរោង ប្រាក់ចំនួន ១០.២៥០ ដុល្លារអាមេរិក

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

≈≈≈

**អនុក្រឹត្យលេខ ២១៧ អនក្រ.តត**

**ស្តីពីការជូនមេដាយសហមេត្រី**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ "សេនា" ជូនលោកស្រី **តាអេកូ តាកាហាស៊ី** (Ms TAEKO TAKAHASHI) ប្រធាននាយកដ្ឋានអាស៊ីអាគ្នេយ៍ទីមួយ នៃអគ្គនាយកដ្ឋានអាស៊ី និងអូសេអានី នៃក្រសួងការបរទេសជប៉ុន ដែលមានស្នាដៃល្អក្នុងការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានរួមចំណែកយ៉ាងសកម្ម នៅក្នុងដំណើរការសន្តិភាពកម្ពុជា ។

**មាត្រា២** .- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

≈≈≈

## អនុក្រឹត្យលេខ ២១៨ អនក្រ.តត

## ស្ដីពីការជូនមេដាយសុវត្ថារា

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

**សំរេច**

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ "**អស្សឫទ្ធិ**" ជូនអនុរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នចំនួន ១២៩ រូប ដែលមានស្នាដៃល្អ ក្នុងការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោមនេះ :

១-ឯកឧត្តម **ប៊ុន អ៊ុយ**

២-ឯកឧត្តម **សេង លឹមនៅ**

៣-ឯកឧត្តម **ម្ស៉ាស់ លាស់**

៤-ឯកឧត្តម **ស្វាយ ស៊ីថា**

៥-ឯកឧត្តម **ផាន់ សួរស័ក្តិ**

៦-ឯកឧត្តម **ហេង ម៉ូរ**

៧-ឯកឧត្តម **នរ៉ាណាវិឆ្ឆិយ៉ាត អាណាវ៉ាន់ដា**

៨-ឯកឧត្តម **ស៊ិន សារុន**

៩-ឯកឧត្តម **ផាន់ នួន**

១០-ឯកឧត្តម **ឡាយ អ៊ីពិសិដ្ឋ**

១១-ឯកឧត្តម **ជុំ សម្ប៉ុន**

១២-ឯកឧត្តម **អ៊ូ គីមឡឿន**

១៣-ឯកឧត្តម **អ៊ុន ចាន់ថា**

១៤-ឯកឧត្តម **លី ឃីម៉ុន**

| | | |
|---|---|---|
| ១៥-ឯកឧត្តម | ប្រាក់ | ហម |
| ១៦-ឯកឧត្តម | កុង | ណែម |
| ១៧-ឯកឧត្តម | ម៉ៅ | សម្បត្តិ |
| ១៨-ឯកឧត្តម | ឌី | ហុក |
| ១៩-ឯកឧត្តម | ឌី | ចន |
| ២០-ឯកឧត្តម | សៀង | ឡាប្រេស្ស |
| ២១-ឯកឧត្តម | ឡុង | វិសាលោ |
| ២២-ឯកឧត្តម | ខុង | សំនួន |
| ២៣-ឯកឧត្តម | ប្រែស | ម៉ាណូឡា |
| ២៤-លោកជំទាវ | ស៊ុន | សារឿន |
| ២៥-ឯកឧត្តម | ម៉ិន | សំ |
| ២៦-ឯកឧត្តម | ទី | គាយី |
| ២៧-ឯកឧត្តម | អ៊ុត | ឈឿន |
| ២៨-ឯកឧត្តម | សូរ | វិចទ័រ |
| ២៩-ឯកឧត្តម | កូច | វណ្ណៈ |
| ៣០-ឯកឧត្តម | អ៊ី | លន់ |
| ៣១-ឯកឧត្តម | ថាច់ | ផែន |
| ៣២-ឯកឧត្តម | អួន | ចន្ទស៊ីយ៉ាវុឌ្ឍ |
| ៣៣-ឯកឧត្តម | ពៅ | យ៉ាដា |
| ៣៤-ឯកឧត្តម | ជន | សាម្ធន |
| ៣៥-ឯកឧត្តម | សៅ | សុភខុន |
| ៣៦-ឯកឧត្តម | ទូ | គីមហៅ |
| ៣៧-ឯកឧត្តម | ជា | ឆាយ |
| ៣៨-ឯកឧត្តម | ធេព | លន់ |

៣៩-ឯកឧត្តម សេង ហាក់ស្រ៊ុន

៤០-ឯកឧត្តម ហ៊ួល លឹម

៤១-ឯកឧត្តម ខ្លួត រ៉ាន់ឌី

៤២-ឯកឧត្តម ញ៉ឹក ទ្រឹង

៤៣-ឯកឧត្តម គោរគ សុវណ្ណារិទ្ធ

៤៤-ឯកឧត្តម គជ ចំនួថា

៤៥-ឯកឧត្តម អ៊ុក ចាយ

៤៦-ឯកឧត្តម សារ៉ាក់ ខាន់

៤៧-ឯកឧត្តម ម៉ែន ហាន

៤៨-ឯកឧត្តម កៅ ខុនដារ៉េត

៤៩-ឯកឧត្តម គឹម សយសាម៉ាឡែន

៥០-ឯកឧត្តម ឱក ប៊ុង

៥១-ឯកឧត្តម ឈឹម ណារិទ្ធ

៥២-ឯកឧត្តម ស៊ឹម កុកហេង

៥៣-ឯកឧត្តម ប៊ុន សុខ

៥៤-ឯកឧត្តម ជ័យ ចាប

៥៥-ឯកឧត្តម ហែម សំកុល

៥៦-ឯកឧត្តម ប៊ូ ជុំសេរី

៥៧-ឯកឧត្តម នូ មុត

៥៨-ឯកឧត្តម ច័ន្ទ សារុន

៥៩-ឯកឧត្តម អ៊ិត ណូឌី

៦០-ឯកឧត្តម តេង ឡៅ

៦១-ឯកឧត្តម មាស គឹមសុវ៉ារូ

៦២-ឯកឧត្តម ឈុន សារ៉េត

៦៣-ឯកឧត្តម ស៊ូ សុវ៉ាត់

៦៤-ឯកឧត្តម ជុំច ភឿន

៦៥-ឯកឧត្តម អ៊ុក សុជាតិ

៦៦-ឯកឧត្តម មីសែល ត្រាណោ

៦៧-ឯកឧត្តម គឹម សុផាត

៦៨-ឯកឧត្តម ពេជ្រ ទុំប្រមិល

៦៩-ឯកឧត្តម ទឹក ភ្លៀនមុន្នា

៧០-ឯកឧត្តម ក្រាជ្ញ ស៊ុន

៧១-ឯកឧត្តម សៀង រ៉ា

៧២-ឯកឧត្តម ទឹម ម៉ានី

៧៣-ឯកឧត្តម រ័ត្ន សណ្ដាប់

៧៤-ឯកឧត្តម ទី ចំនួនផល

៧៥-ឯកឧត្តម សួស គង់

៧៦-ឯកឧត្តម ម៉ក់ សុភី

៧៧-ឯកឧត្តម ជី សុណា

៧៨-ឯកឧត្តម ឡេង តឹកសេន

៧៩-ឯកឧត្តម យី យ៉ុន

៨០-ឯកឧត្តម សយ ស៊ីផន

៨១-ឯកឧត្តម ទេង សុត្រា

៨២-ឯកឧត្តម នួន ភារិទ្ធ

៨៣-ឯកឧត្តម យូ មុណ្យណា

៨៤-ឯកឧត្តម ឡា ណារ៉ាត

៨៥-ឯកឧត្តម ឡុង វ៉ាន់ឋាន

៨៦-ឯកឧត្តម រស់ សម៉ិយ

៨៧-ឯកឧត្តម ភូយ គីមស៊ា
៨៨-ឯកឧត្តម ម៉ា សូផាន់ណា
៨៩-ឯកឧត្តម ដោក ណារិន
៩០-ឯកឧត្តម ហ្សាការីយ៉ា អាដាម
៩១-ឯកឧត្តម អ៊ីស្មាឯល ឧស្មាន
៩២-ឯកឧត្តម គ្រួច សារី
៩៣-ឯកឧត្តម សៅ ច័ន
៩៤-លោកជំទាវ សាន អារុន
៩៥-ឯកឧត្តម សោម ចំឡង៉ែម
៩៦-លោកជំទាវ ឃឹម ចំរើន
៩៧-លោកជំទាវ អ៊ុំ ចន្ថា
៩៨-លោកជំទាវ ឡូច ស៊ីវដ្ឋា
៩៩-ឯកឧត្តម អ៊ុក ចាន់
១០០-ឯកឧត្តម កែប ជុន
១០១-ឯកឧត្តម ភុយ គីមជន
១០២-ឯកឧត្តម ស្ងួន ហោង
១០៣-ឯកឧត្តម តាន់ ស៊ិនតូ
១០៤-ឯកឧត្តម អ៊ិន នាង
១០៥-ឯកឧត្តម អ៊ី ជន
១០៦-ឯកឧត្តម ប៉ុក ម៉ាន់នី
១០៧-ឯកឧត្តម សុទ្ធ សុធន្ទ
១០៨-ឯកឧត្តម អ៊ុំ ម៉ុនធឿន
១០៩-ឯកឧត្តម ជ័យ សម្បូណ៌
១១០-លោកជំទាវ ខ្ញឹម សោមស៊ុន

១១១-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវណ្ណារាមុទ្ធិ**

១១២-ឯកឧត្តម **ម៉ម សូផាណា**

១១៣-ឯកឧត្តម **វ៉ែន សារិន**

១១៤-ឯកឧត្តម **ព្រហ្ម សិទ្ធត្រា**

១១៥-ឯកឧត្តម **កែវ ខេមរា**

១១៦-ឯកឧត្តម **កើត សារ៉េត**

១១៧-ឯកឧត្តម **ម៉ើង សាខុន**

១១៨-ឯកឧត្តម **ផង់ សារ៉េត**

១១៩-ឯកឧត្តម **សំ សារិត**

១២០-ឯកឧត្តម **តុំ ប៊ុនឡៀន**

១២១-ឯកឧត្តម **អឿ ហ៊ុនលី**

១២២-ឯកឧត្តម **ម៉ែន គួន**

១២៣-ឯកឧត្តម **អៀម សារុំ**

១២៤-ឯកឧត្តម **មូង សៅខន**

១២៥-ឯកឧត្តម **ជុំ អៀក**

១២៦-ឯកឧត្តម **តាន់ ទុដ្ឋា**

១២៧-ឯកឧត្តម **កែវ សាផល**

១២៨-ឯកឧត្តម **ឆា សុថ្ថា**

១២៩-ឯកឧត្តម **ម៉ៅ ហាវណ្ណាល់**

មាត្រា២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២១៩ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុរាជក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា១** .- តែងតាំងមន្ត្រីរាជការចំនួន ០២ រូប របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានរាយនាមខាងក្រោមនេះ :

១-លោក **ជួប សំអាត** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទ

២-លោក **ខា ហៀង** ជាអធិការ នៃអគ្គាធិការដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទ

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

ហ៊ុន សែន

# អនុក្រឹត្យលេខ ២២០ អនក្រ.តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

## សំរេច

**មាត្រា១ ..** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឃួន ឃុននាយ** ប្រធានសមាគមគេបិចកម្ពុជា ដែលបានជួយកសាងអាគារសិក្សា ០១ ខ្នង មាន ០៣ បន្ទប់ ធ្វើអំពីឥដ្ឋ ប្រក់សង្កសី បង្គន់អនាម័យ ០២ បន្ទប់ និងបំពាក់សង្ហារឹមគ្រប់ចំនួន សរុបទឹកប្រាក់ចំនួន ៣៣.៥០០ ដុល្លារអាមេរិក ស្ថិតនៅក្នុងសាលាបឋមសិក្សាគោកបញ្ជាន់ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

**មាត្រា២ ..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

# អនុក្រឹត្យលេខ ២២១ អនក្រ.តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សំរេច

**មាត្រា១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអ្នកស្រី **សឹង សីមួយ** និងលោក **ម៉ែន គីមប៊ុន** ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីជួសជុល និងរចនាកែលំអឧបដ្ឋានសាលាអោយមានសោភណភាពយ៉ាងល្អប្រណិត គួរជាទីមនោរម្យនៃពុទ្ធសាសនិកសរុបទឹកប្រាក់ចំនួន ១០.៥០០ ដុល្លារអាមេរិក ស្ថិតនៅក្នុងវត្តធម្មកេរ្តិ៍ ឃុំកញ្ច្រៀច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង។

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

# អនុក្រឹត្យលេខ ២២២ អនក្រ.តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ០៧ រូប ដែលបានបរិច្ចាគនូវបច្ច័យ និងថវិកាផ្ទាល់រៀង១ខ្លួន ដើម្បីជួយកសាង និងជួសជុលសមិទ្ធផលនានា ជាច្រើនដូចជាកសាងព្រះវិហារ ដងទង់ កុដិ សាលាបុណ្យ រោងបាយ ទូកង ស្ពាន បង្គន់អនាម័យ នៅវត្តពោធិចារ្យ ស្រុកល្វាឯម និងជួសជុលអាគារសិក្សា ៦ ខ្នង នៅសាលាបឋមសិក្សាពោធិមាស ព្រៃគគង់រាជ និងសាលាបឋមសិក្សាភូមិធំ ក្នុងស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

១-ព្រះតេជគុណ **ឌួង សំណាង** បច្ច័យចំនួន ១៨.០០០ USD

២-ព្រះតេជគុណ **ឌូច រ៉ន** បច្ច័យចំនួន ១២.០០០ USD

៣-លោក **ម៉ិន ផេង** ថវិកាចំនួន ១០.៥០០ USD

៤-លោក **ពិន សារិន** ថវិកាចំនួន ១២.៣០០ USD

៥-លោក **អ៊ូ ហុកគាំង** ថវិកាចំនួន ១២.៥០០ USD

៦-លោក **ឌា ឈុនហុក** ថវិកាចំនួន ១១.២៥០ USD

៧-លោក **លីឆុង ម៉េងរី** ថវិកាចំនួន ១១.៧០០ USD

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១**

**នាយករដ្ឋមន្ត្រី**

**សម្តេចហ៊ុន សែន**

**ហ៊ុន សែន**

===

## អនុក្រឹត្យលេខ ២២៣ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ១៩ រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាផ្ទាល់រៀងៗខ្លួន ដើម្បីកសាងព្រះវិហារ និង សមិទ្ធផល

នានាជាច្រើន ស្ថិតនៅក្នុងវត្តវេឡុវ៉ែន ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម :

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោកគ្រូ ធម្មាចារ្យសោភណត្ថេរ **សោម សុភាព** ចៅអធិការវត្តវេឡុវ៉ែន បច្ច័យចំនួន ៧៥.៩៩៩,៦២ USD និង ៥០.៦៤៤.៦០០ រៀល ,

២-លោក **ចាប ម៉ុច** ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ថវិកាចំនួន ២០.០០០ USD

៣-លោក **ម៉ុន ហេង** និងអ្នកស្រី **ជុំ សុខុម** អាណិកជនខ្មែរ នៅអូស្ត្រាលី ថវិកាចំនួន ១៣.៥០០ USD

៤-លោកស្រី **ញឹក ម៉ុនថា** នៅភ្នំពេញ ថវិកាចំនួន ១០.០០០ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោកស្រី **ស៊ីវ យក់លុយ** អាណិកជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.៥០០ USD

២-លោក **ឆាយ ស៊ីវសៀង** និងលោកស្រី **ហុង គីមសែ** អាណិកជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.០០០ USD

៣-លោកស្រី **លាស់ ស៊ឹម** អាណិកជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.០០០ USD

៤-លោក **ស៊ុន ដារិន** និងលោកស្រី **ចាន្លី** អាណិកជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.០០០ USD

៥-លោក **អ៊ីវ ស្រេងលីម** និងលោកស្រី **ឃឹម ម៉ាត** អាណិកជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.០០០ USD

៦-លោកជំទាវ **អ៊ុំ ស៊ីវអៀង** នៅភ្នំពេញ ថវិកាចំនួន ៥.០០០ USD

៧-លោកស្រី **ឡោក ខុក** នៅភ្នំពេញ ថវិកាចំនួន ៥.០០០ USD

៨-លោក **ឃុន ថុង** និងអ្នកស្រី **បុប្ផាណា** នៅភ្នំពេញ ថវិកាចំនួន ៥.០០០ USD

៩-លោក **ហួ ស្រី** និងអ្នកស្រី **ចាន់ លី** នៅភ្នំពេញ ថវិកាចំនួន ៥.០០០ USD

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោកស្រី **នុត ព្រីដា** នៅភ្នំពេញ ថវិកាចំនួន ៤.០០០ USD

២-លោក **នូ ម៉ុនចាន់** នៅភ្នំពេញ ថវិកាចំនួន ៣.០០០ USD

៣-លោក **មុត សំអាត** និងអ្នកស្រី **ចាន់នី** នៅឃុំបឹងធំ ថវិកាចំនួន ៣.០០០ USD

៤-លោក **កែត ហៀង** ប្រធានគណៈកម្មការវត្ត ថវិកាចំនួន ៣.០០០ USD

៥-លោក **នៅ ជួន** នៅឃុំបឹងធំ ថវិកាចំនួន ២.០០០ USD

៦-លោក **ឃូ សៀងខូនលី** អាណិកជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.០០០ USD

**មាត្រា២ ..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

====

**អនុក្រឹត្យលេខ ២២៤ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់របស់ខ្លួន ដើម្បីកសាងសាលារៀនខ្មែរ-ចិន **ចេង ម៉េង** ចំនួន ០៣ ខ្នង មាន ១៣ បន្ទប់ ធ្វើអំពីបេតុង ប្រក់ហ្វីប្រូស៊ីម៉ង់ត៍ និងក្បឿង ស្ថិតនៅក្នុងភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

១-លោកឧកញ៉ា **ដួង ឈីច** ប្រធានសមាគមចិន នៅព្រះរាជាណាចក្រកម្ពុជា ថវិកាចំនួន ១០.៥០០ USD

២-លោក **យូ សៀង** ប្រធានគណៈកម្មការសាងសង់សាលា និងជាអនុប្រធានសមាគមចិននៅព្រះរាជាណាចក្រកម្ពុជា ថវិកាចំនួន ១៣.០០០ USD

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

**អនុក្រឹត្យលេខ ២២៥ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា១ .-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និងជូនសប្បុរសជនដែលបានខិតខំប្រឹងប្រែងរួមចំណែកជួយកសាងសមិទ្ធផលនានាជាច្រើន ដូចជាកសាងធម្មកុដិ ហោត្រ័យ ម៉ាស៊ីនភ្លើង ក្លោងទ្វារ សាលារៀន អាងទឹក និងចាក់បេតុងទីធ្លាវត្ត ស្ថិតនៅវត្តអង្គត្រគៀត ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម :

**ក.-មេដាយមាសស្ថាបនាជាតិ :**

-ព្រះតេជគុណ **សួន យឿង** ចៅអធិការវត្តអង្គត្រគៀត បច្ច័យចំនួន ១៨១.៣៧៥ USD

**ខ.-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **គុយ គាំងអ៊ុន** អាចារ្យវត្តអង្គត្រគៀត ថវិកាចំនួន ៩.០០០ USD

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

**អនុក្រឹត្យលេខ ២២៦ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្ដាល

**សំរេច**

**មាត្រា១ ..** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ០៥ រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាផ្ទាល់ខ្លួន ដើម្បីកសាងអាគារសិក្សាចំនួន ០៣ ខ្នង មាន ១៥ បន្ទប់ ធ្វើអំពីបេតុង ប្រក់ក្បឿង ព្រមទាំងបំពាក់សំភារៈបរិក្ខារសិក្សាគ្រប់ចំនួន ស្ថិតនៅក្នុងសាលាបឋមសិក្សាសំប៉ាន ឃុំកោះធំ (ខ) ស្រុកកោះធំ ខេត្តកណ្ដាល ដូចមានរាយព្រះនាម និងនាមខាងក្រោម :

១-ព្រះតេជគុណ **អេង ណាំ** ចៅអធិការវត្តសំប៉ាន បច្ច័យចំនួន ១០.០០០ USD

២-លោកវរសេនីយ៍ឯក **ប៊ុក ស៊ីនហួ** ថវិកាចំនួន ៣០.០១៥ USD

៣-លោក **ថោ ស៊ិន** តំណាងអាណិកជនខ្មែរនៅប្រទេសបារាំង ថវិកាចំនួន ១២.០០០ USD

៤-លោក **ម៉ឹង ឈីវ** ប្រធានសហគមន៍ ថវិកាចំនួន ១០.០០០ USD

៥-លោក **ឡេង ម្រាង** ប្រធានគណៈកម្មការសាងសង់ ថវិកាចំនួន ១០.០០០ USD

**មាត្រា២ ..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២២៧ អនក្រ.តត
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពត

## សំរេច

**មាត្រា១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនក្រៅប្រទេសចំនួន ០៥ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តអម្ពវ័នយោធារាម (ទូលផ្ទឹក) និងវត្តបាលិលេយ្យ ក្នុងស្រុកជុំគីរី ខេត្តកំពត ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | **ស័ព្វ គួន** | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ២៣.០០០ USD |
| ២-លោកស្រី | **តាន់ គៀង** | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ២០.០០០ USD |
| ៣-លោកស្រី | **មួន គីមឡាយ** | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ១៨.០០០ USD |
| ៤-លោកស្រី | **តឹក ហោ** | នៅប្រទេសបារាំង | ទឹកប្រាក់ចំនួន ១២.៨០០ USD |
| ៥-លោកស្រី | **តឹក ស្រួយ** | នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ១២.០៨៦ USD |

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២២៨ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក/ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១** .- ត្រូវបានតែងតាំងលោក **ម៉ុន ខេង** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាមានឋានៈស្មើ អគ្គនាយករង ។

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

## ២_សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេច ២៧ សសរ**

**ស្តីពីការបង្កើតក្រុមចរចារវាងរាជរដ្ឋាភិបាល និងធនាគារពិភពលោក**

**សំរាប់គំរោងរំសាយទ័ពនៃកម្មវិធីជំនួយឧបត្ថម្ភអតីតយុទ្ធជនកម្ពុជា**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

-យោងតាមសេចក្តីត្រូវការចាំបាច់របស់ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

**សំរេច**

**ប្រការ១** : បង្កើតក្រុមចរចារបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចរចាជាមួយធនាគារពិភពលោក ស្តីពីឥណទានសំរាប់ដំណើរការគំរោងរំសាយទ័ព នៃកម្មវិធីជំនួយឧបត្ថម្ភអតីតយុទ្ធជនកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាប្រធាន

២-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ និងអនុប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាសមាជិក

៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក **មាស សុភា** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាអនុប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាសមាជិក

៤-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាសមាជិក

៥-ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃ ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាសមាជិក

៦-ឯកឧត្តម **ព្រាំ សំអុល** អគ្គលេខាធិការរងនៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាសមាជិក

៧-ឯកឧត្តម **ខៀវ ឆេន** អគ្គលេខាធិការរងនៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាសមាជិក

៨-លោក **ថោង សុជាតិ** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ជាលេខាធិការ

**ប្រការ២ :** ក្រុមចរចានេះមានតួនាទី និង ភារកិច្ចដូចខាងក្រោមនេះ :

១-សហការ សម្របសម្រួល និងបំពេញការងារជាមួយក្រុមបេសកកម្មរបស់ធនាគារពិភពលោក ដើម្បីធ្វើការសិក្សា និងវាយតំលៃគំរោងរំសាយទ័ពនៃកម្មវិធីជំនួយឧបត្ថម្ភអតីតយុទ្ធជនកម្ពុជា ។

២-សហការជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរៀបចំបណ្តាលិខិតបទដ្ឋានចាំបាច់សំរាប់បំរើអោយការងារវាយតំលៃ និងចរចាស្តីពីឥណទានសំរាប់ដំណើរការគំរោងរំសាយទ័ពនេះ ។

៣-ធ្វើការចរចាជាផ្លូវការ និង អនុម័តជំនួសមុខអោយរាជរដ្ឋាភិបាលកម្ពុជាជាមួយតំណាងស្របច្បាប់របស់ធនាគារពិភពលោក ស្តីពីប្រាក់កម្ចីនេះ ដើម្បីយកមកប្រើប្រាស់អនុវត្តកម្មវិធីរំសាយទ័ព ។

៤-សរុបរបាយការណ៍ ស្តីពីការចរចាជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាវាយកងកំលាំងប្រដាប់អាវុធ ឯកឧត្តម និងអស់លោកដែលមានឈ្មោះនៅក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

## សេចក្តីសំរេច ២៨ សសរ

## ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យការសាងសង់ស្ពាន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការ ដើម្បីត្រួតពិនិត្យ និងជួយសំរួលក្នុងការសាងសង់ស្ពាន ដែលឧបត្ថម្ភដោយសប្បុរសជន សញ្ជាតិ ស្វីស លោក Toni Ruttimann ដូចមានសមាសភាពខាងក្រោម :

១-ឯកឧត្តម **សុខ អាន** ប្រធាន

២-ឯកឧត្តម **គន់ គីម** អនុប្រធាន

៣-ឯកឧត្តម **សម សុគន្ធា** អនុប្រធានអចិន្ត្រៃយ៍

៤-ឯកឧត្តម **ម៉ុង សំផន** អនុប្រធាន

៥-ឯកឧត្តម **ថោង ខុន** សមាជិក

៦-ឯកឧត្តម **យឹម នៃលី** សមាជិក

៧-ឯកឧត្តម **អ៊ុក ចាន់** សមាជិក

៨-ឯកឧត្តម **អ៊ុត ឈន** សមាជិក

៩-ឯកឧត្តម **ខ្វាន់ ស៊ាង** សមាជិក

១០-ឯកឧត្តម **អភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ** សមាជិក

**ប្រការ២** : គណៈកម្មការនេះមានភារកិច្ច :

-ពិនិត្យទីកន្លែងដែលចាំបាច់ត្រូវសាងសង់ស្ពាន នៅតាមបណ្តាខេត្ត ក្រុងមួយចំនួន ដើម្បីសាងសង់ ។

-ជួយសំរួលដល់លោក Toni Ruttimann ក្នុងការនាំចូល លើកដាក់ ដឹកជញ្ជូនសំភារៈអោយទៅដល់ការដ្ឋាន និងផ្តល់ការឧបត្ថម្ភជាមធ្យោបាយសំភារៈចាំបាច់ ក្នុងការសាងសង់ស្ពាន ។

-ជួយសំរបសំរួលជាមួយអាជ្ញាធរខេត្ត ក្រុង ដែលពាក់ព័ន្ធ និងសហគមន៍ និងជួយចលនាមហាជនអោយចូលរួមចំណែកដើម្បីដំណើរការនៃសាងសង់ស្ពានអោយបានល្អ ។

-គណៈកម្មការមានសេនាធិការដ្ឋាននៅទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

-សមាសភាពគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៣** : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរខេត្ត ក្រុង ដែលពាក់ព័ន្ធ និងសមាសភាពដូចមាន

ចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

## ៣_សារាចរណែនាំ

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០១

**សារាចរណែនាំ លេខ ០៨ សរណន**

**ស្ដីពីការរៀបចំយុទ្ធនាការ "ផ្ដល់ការគាំទ្រចំពោះកុមារ"**

ក្នុងគោលបំណងពង្រឹងពង្រីកសកម្មភាព សំដៅធ្វើអោយកុមារទទួលបាននូវសិទ្ធិកាន់តែល្អប្រសើរឡើងថែមទៀត និងដើម្បីចូលរួម **"ចលនាពិភពលោកដើម្បីកុមារ"** ដែលមានព្រឹត្តិការណ៍សំខាន់ៗដូចជា ការពិនិត្យ ឡើងវិញនូវស្ថានភាពរបស់កុមារ ការវាយតំលៃលើការរីកចំរើនដែលបានអនុវត្តតាមកម្មវិធីអន្តរជាតិ ដើម្បីកុមារ ឆ្នាំ ១៩៩០ ការធ្វើយុទ្ធនាការផ្ដល់ការគាំទ្រចំពោះកុមារ និងការប្រជុំអំពីកុមារជាបន្តបន្ទាប់ ហើយសម័យប្រជុំ ពិសេសអំពីកុមារនៃមហាសន្និបាតអង្គការសហប្រជាជាតិ ដែលនឹងប្រព្រឹត្តទៅក្នុងខែកញ្ញា ឆ្នាំ ២០០១ នាពេលខាងមុខ នៅទីក្រុងញូវយ៉ក ដោយមានប្រទេសហត្ថលេខីជាច្រើនចូលរួម ។

កន្លងមក ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិកុមារនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ ហើយត្រូវចូលរួមចំណែកក្នុងចលនាពិភពលោកដើម្បីកុមារ និងបង្កើនកិច្ចគាំទ្រដល់កុមារកម្ពុជា ដែលជាអ្នកបន្តវេនសំរាប់អនាគតនៃប្រទេសជាតិ ។ កាលពីថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានធ្វើសេចក្ដីថ្លែងការណ៍បើកយុទ្ធនាការ និងចុះហត្ថលេខាលើប័ណ្ណ **"ផ្ដល់ការគាំទ្រចំពោះកុមារ"** ដោយបានអំពាវនាវដល់ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ បញ្ញវ័ន្ត ព្រះសង្ឃ ប្រជាពលរដ្ឋ កុមារា និងកុមារី អោយចូលរួមយ៉ាងសកម្មក្នុងចលនា

ផ្តល់មតិ និងចុះហត្ថលេខាលើខិត្តប័ណ្ណ **"ផ្តល់ការគាំទ្រចំពោះកុមារ"** ព្រមទាំងចូលរួមសកម្មភាពផ្សេងៗ ទៀតសំរាប់កុមារ ។

ដើម្បីអនុវត្តតាមស្មារតីខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំដូចតទៅ :

**១-ការធ្វើយុទ្ធនាការ "ផ្តល់ការគាំទ្រចំពោះកុមារ"**

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវរៀបចំយុទ្ធនាការ **"ផ្តល់ការគាំទ្រចំពោះកុមារ"** ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

-ក្រសួងអប់រំយុវជន និងកីឡា សហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវរៀបចំក្រុមលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ដើម្បីចូលរួមសកម្មភាពយុទ្ធនាការ ។

-ក្រសួងធម្មការ និងសាសនា ត្រូវចូលរួមសកម្មភាពយុទ្ធនាការដោយសុំហត្ថលេខាពីព្រះសង្ឃ ។

-អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ត្រូវចូលរួមសហការ និងគាំទ្រដល់សកម្មភាពយុទ្ធនាការនៅក្នុងមូលដ្ឋានរបស់ខ្លួន ។

-គ្រប់ក្រសួង-ស្ថាប័ន ត្រូវបំផុសចលនាដល់មន្ត្រីរាជការក្រោមឱវាទ ចូលរួមសកម្មភាពយុទ្ធនាការ និងចុះហត្ថលេខាលើខិត្តប័ណ្ណ **"ផ្តល់ការគាំទ្រចំពោះកុមារ"** ។

**២-ការធ្វើព្យុហយាត្រា**

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងអប់រំយុវជន និងកីឡា ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងអង្គការក្រៅរដ្ឋាភិបាលនានា ត្រូវរៀបចំព្យុហយាត្រានៅវិមានឯករាជ្យនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ អោយបានយ៉ាងឱឡារិក អធិកអម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ។

**៣-ការធ្វើសេចក្តីរាយការណ៍**

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវរៀបចំគណៈប្រតិភូ និងឯកសារដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា អំពីលទ្ធផលយុទ្ធនាការ **"ផ្តល់ការគាំទ្រចំពោះកុមារ"** និងសហការជាមួយអង្គការ យូនីសេហ្វ ដើម្បីបញ្ជូនលទ្ធផលបូកសរុបទៅទីក្រុងញូវយ៉ក ។

៤-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយសំភារៈ ថវិកា សំរាប់អនុវត្តយុទ្ធនាការនេះឱ្យបានទាន់ពេលវេលា ដើម្បីធានាការចាត់តាំងសមស្របតាមគោលបំណង និងសំណូមពរ ។

រាជរដ្ឋាភិបាល សូមអំពាវនាវដល់ អង្គការជាតិ-អន្តរជាតិ ផ្នែកឯកជន និងប្រជាពលរដ្ឋ សូមជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីទាំងនេះអោយបានផុលផុស អធិកអធម ។

ទទួលបាននូវសារាចរណែនាំនេះ សូមឯកឧត្តមថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្ត ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

## III- ការងារបណ្ដាក្រសួង

### ១-ឯកសារ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០១

**ប្រកាសលេខ ៣២៩ ឧរថក២.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្ដេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្តលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២២១០/០០ គ.វ.ក ចុះថ្ងៃទី ០៤-៨-២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

-បានឃើញលិខិតលេខ ១៤៣៤ ប.ស្ថ សណ ចុះថ្ងៃទី ២៧-១២-២០០០ របស់ក្រសួងបរិស្ថាន

-បានឃើញលិខិតលេខ ៨៤៨ ឆត.ស ចុះថ្ងៃទី ១០-៥-២០០១ របស់សាលាក្រុងភ្នំពេញ ។

-យោងពាក្យស្នើរបស់ក្រុមហ៊ុន ស៊ីណូ-ណេឈ័រ ហ្គាមេន (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី ១៤-៣-២០០១ ។

**សំរេច**

**ប្រការ១** : អនុញ្ញាតអោយក្រុមហ៊ុន ស៊ីណូ-ណេឈ័រ ហ្គាមេន (ខេមបូឌា) ខូ អិលធីឌី (SINO-NATURE GARMENTS(CAMBODIA) Co, LTD) តំណាងដោយលោក LAM KAM CHUEN SAMUEL សញ្ជាតិ អង់គ្លេស ភេទប្រុស អាយុ ៣៨ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ ៦២០៣១០៨៤៧ ចុះថ្ងៃទី ៣១-៨-១៩៩៣ បង្កើតរោងចក្រផលិតសំលៀកបំពាក់នាំចេញ ដែលមានផ្លាកឈ្មោះថា " ស៊ីណូ-ណេឈ័រ ហ្គាមេន (ខេមបូឌា) ខូ អិលធីឌី " មានទីតាំងស្ថិតនៅផ្លូវទ្រូងមាន់ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**ប្រការ២** : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣** : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ "កាត់-ដេរសំលៀកបំពាក់ " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៤** : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ៥** : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៦** : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវស៊ើវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ៧** : ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ៨** : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ៩** : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ស៊ីណូ-ណេឈ័រ ហ្គាមេន (ខេមបូឌា) ខូអិល ធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១០** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ហត្ថលេខា និងត្រា**

**ស៊ុយ សែម**

===

## ២-នីតិការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ប្រកាស**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧកភា ឆ្នាំ ២០០១

### ប្រកាសលេខ ១៩១ ប្រក.កសក

### ស្តីពីវិធានការទប់ស្កាត់ការនាំចូលសត្វគោ សត្វទំពារអៀង និងផលិតផលមានដើមកំណើតពីសត្វគោ សត្វទំពារអៀង ពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា

---

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញសេចក្តីសំរេចលេខ ០៥ សសរ ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់ការនាំចូលតាមច្រកព្រំដែននូវសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគ ដែលបណ្តាលអោយប៉ះពាល់ដល់សុខភាពសាធារណៈ

-បានឃើញលិខិតលេខ ២៧៨ សជណ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីជំងឺគោឆ្កួតនៅ ១៣ ប្រទេសនៃទ្វីបអឺរ៉ុប និងវិធានការទប់ស្កាត់

-បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**ប្រការ១** : ហាមឃាត់ការនាំចូលសត្វគោ សត្វទំពារអៀង និង ផលិតផលមានដើមកំណើតពីសត្វគោ និងសត្វទំពារអៀង ពីប្រទេសចំនួន ១៣ នៃសហគមន៍អឺរ៉ុប ( អង់គ្លេស បែលហ្ស៊ិក ដាណឺម៉ាក បារាំង អាល្លឺម៉ង់ អៀរឡង់ លុចសំបួរ ហូឡង់ ព័រទុយហ្គាល់ អេស្ប៉ាញ ស្វ៊ីស កាណាដា និង អ៊ីតាលី ) ។

**ប្រការ២** : ការនាំចូលសត្វគោ សត្វទំពារអៀង និងផលិតផលមានដើមកំណើតពីសត្វគោ និងសត្វទំពារអៀង ពីបណ្តាប្រទេសផ្សេងៗ ទៀត ដែលពុំមានបញ្ជាក់ថាមានជំងឺ BSE ភាសាសាមញ្ញហៅថាជំងឺគោឆ្កួត ចាំបាច់ត្រូវមានគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថិតក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់នាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាល ។

**ប្រការ៣** : ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស អគ្គនាយកក្រសួង អគ្គាធិការ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ប្រធានមន្ទីរកសិកម្ម រុក្ខា

ប្រមាញ់ និងនេសាទគ្រប់ខេត្ត-ក្រុង ត្រូវទទួលអនុវត្តសេចក្ដីប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា.និងត្រា
**ម៉ែន សំអឿន**